អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ថ្ងៃទី ២៦ ខែមីនា ឆ្នាំ ២០១២

# សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតជាតិ

នាថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១២ លោកសហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិបានធ្វើសេចក្តីប្រកាសព័ត៌មានមួយ និងដាក់ឯកសារមួយចំនួនជាសាធារណៈ ដែលតម្រូវឲ្យមានការបកស្រាយពីសំណាក់សហចៅក្រមស៊ើបអង្កេតជាតិនូវចំនុច ដែលទាក់ទងទៅនឹងការិយាល័យនេះ ដើម្បីជៀសវាងនូវការភ័ន្តច្រឡំនានាពីសាធារណជន។

**១. ការមិនទទួលស្គាល់ ឬគាំទ្រនូវជំហររបស់ចៅក្រម Laurent Kasper-Ansermet ជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ៖**

មុនមកដល់ទីក្រុងភ្នំពេញ លោកចៅក្រមបម្រុង បានផ្ញើសារអេឡិចត្រូនិកមកសហចៅក្រមជាតិ នាថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ ដោយស្នើសុំជួបសហចៅក្រមជាតិនៅ អ.វ.ត.ក ដើម្បីពិភាក្សាអំពីចំណាត់ការនីតិវិធីពាក់ព័ន្ធនឹងសំណុំរឿង ០០៣ និង ០០៤ និងបានលើកឡើងថា រាជរដ្ឋាភិបាលកម្ពុជាជំទាស់មិនឲ្យគាត់មកកាន់ព្រះរាជាណាចក្រកម្ពុជាទេ[1] ដែលសហចៅក្រមស៊ើបអង្កេតជាតិជឿថា ការលើកឡើងរបស់គាត់គឺជាការបំផ្លើសដោយហេតុថា ប៉ុន្មានថ្ងៃបន្ទាប់ពីនោះគាត់ក៏មកអង្គុយនៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេតនៃអ.វ.ត.ក។ ភ្លាមៗពេលមកដល់ នាថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ២០១១ លោកចៅក្រមបានផ្ញើជូនសហចៅក្រមស៊ើបអង្កេតជាតិនូវសេចក្តីព្រាងដីកាសម្រេចស្តីអំពីការបើកការស៊ើបអង្កេតបឋមសំណុំរឿង ០០៣ ឡើងវិញ[2] ដោយមិនទាន់ទាំងបានជួបគ្នាជជែកពិភាក្សាម្តងណាសោះ ។ នាថ្ងៃទី ០៥ ខែធ្នូ ឆ្នាំ ២០១១ សហចៅក្រមជាតិបានជួបជាមួយនឹងលោកចៅក្រម Laurent Kasper Ansermet ដោយបានគូសបញ្ជាក់ទៅគាត់ថា *"ខ្ញុំមិនអាចនឹងពិភាក្សាអំពីសំណុំរឿង ឬធ្វើចំណាត់ការនីតិវិធីណាមួយជាមួយលោកចៅក្រមបម្រុងឡើយ ក្នុងករណីដែលតំណែងសហចៅក្រមស៊ើបអង្កេតអន្តរជាតិនៅទំនេរ ព្រោះថា ស្របតាមគោលការណ៍ដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង មាត្រា ២៦ និងមាត្រា ២៧ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៣ និង មាត្រា ៥.៦ នៃកិច្ចព្រមព្រៀង តម្រូវឲ្យមានការតែងតាំងសហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិជាចៅក្រមពេញសិទ្ធិ ដែលនេះជាការអនុវត្តដូចគ្នាទៅនឹងសហចៅក្រមស៊ើបអង្កេត Siegfried Blunk នៅពេលដែល*

---

[1] សារអេឡិចត្រូនិកចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១ ។

[2] លិខិតចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១១ និងសេចក្តីព្រាងដីកាសម្រេចស្តីអំពីការបើកការស៊ើបអង្កេតបឋមឡើងវិញ ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១១ ។

*ជំនួសលោកចៅក្រម Marcel Lemonde។ ដូចនេះលោកចៅក្រមបម្រុងគួររង់ចាំការតែងតាំងជាចៅក្រមពេញសិទ្ធិជាមុនសិន។ ម្យ៉ាងវិញទៀត ចំណាត់ការតាមបែបប្រញ៉ាប់ប្រញ៉ាល់របស់លោកសហចៅក្រមបម្រុងមិនផ្តល់អ្វីជាផលប្រយោជន៍រួមនៃសំណុំរឿង ០០៣ និង ០០៤ ក៏ដូចជាការិយាល័យសហចៅក្រមស៊ើបអង្កេតទាំងមូលនោះឡើយ ហើយលោកចៅក្រមបម្រុងគួរតែយកពេលវេលារង់ចាំនេះសិក្សាសំណុំរឿងសិន ព្រោះថាសំណុំរឿងមានឯកសារមូលដ្ឋានច្រើនណាស់ ហើយក៏ត្រូវស្វែងយល់អំពីនីតិវិធីអនុវត្តនៅអ.វ.ត.កផងដែរ ដូចជាឯកសាររបស់លោកដែលប្រើពាក្យថា សុំបើក "ការអង្កេតបឋម" ឡើងវិញនេះ មិនត្រឹមត្រូវទេ ព្រោះថានីតិវិធីអង្កេតបឋម គេប្រើតែក្នុងដំណាក់កាលសហព្រះរាជអាជ្ញាប៉ុណ្ណោះ ចំណែកនៅដំណាក់កាលសហចៅក្រមស៊ើបអង្កេត គេប្រើនីតិវិធីនៃការស៊ើបសួរ"។* លោកសហចៅក្រមបម្រុង Laurent Kasper Ansermet បានទទួលស្គាល់ថា ខ្លួនមិនទាន់បានពិនិត្យមើលសំណុំរឿងនៅឡើយ ប៉ុន្តែការស្នើភ្លាមៗនូវការបើកការស៊ើបអង្កេតឡើងវិញក្នុងសំណុំរឿង ០០៣ នេះ ព្រោះខ្លួនបារម្ភខ្លាចសហចៅក្រមស៊ើបអង្កេតជាតិផ្ញើនូវដីកាបញ្ជូនរឿងទៅពិនិត្យមូល ទៅសហព្រះរាជអាជ្ញា។ ជាការឆ្លើយតប សហចៅក្រមស៊ើបអង្កេតជាតិបានបំភ្លឺថា "*ដីកាបញ្ជូនរឿងទៅពិនិត្យមូលនេះ ត្រូវបានព្រាងដោយសហចៅក្រមស៊ើបអង្កេតជាតិ និងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ Siegfried Blunk យូរខែណាស់មកហើយ ប៉ុន្តែនាពេលដែលចៅក្រម Blunk នៅកាន់តំណែង យើងមិនទាន់អាចចុះហត្ថលេខាលើដីកានោះបាន ដោយហេតុថា មានភាពយឺតយ៉ាវ ដែលគ្មានការពន្យល់ហេតុផលណាមួយសមស្របក្នុងការសម្រេចរបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ។ នាពេលនេះ ដោយហេតុថា មិនទាន់មានសហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលមាននីតិសម្បទាក្នុងការសម្រេចសេចក្តីជាមួយសហចៅក្រមជាតិលើបញ្ហាដីកាបញ្ជូនរឿងទៅពិនិត្យនេះ ទើបសហចៅក្រមស៊ើបអង្កេតជាតិមិនអាចបញ្ជូនដីកានេះ ទៅសហព្រះរាជអាជ្ញាបាន ហើយក៏មិនប្រញាប់ប្រញាល់បំពេញកិច្ចនាំឲ្យខុសនីតិវិធីឡើយ"*។

ដោយហេតុថា លោកចៅក្រមបម្រុង Laurent Kasper Ansermet នៅតែចចេស និងទាមទារឲ្យមានការឆ្លើយតបជាលាយលក្ខណ៍អក្សរ សហចៅក្រមជាតិបានផ្ញើអនុស្សរណៈផ្ទៃក្នុងមួយជូនលោកចៅក្រមបម្រុង ដោយបានបញ្ជាក់ច្បាស់ជាថ្មីម្តងទៀតថា៖ "*អំពីការចាប់ផ្តើមចំណាត់ការនីតិវិធីដែលខ្ញុំអាចពិភាក្សាជាមួយលោកចៅក្រមបាន គឺក្រោយពេលមានការតែងតាំងលោកចៅក្រមដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនៃព្រះរាជាណាចក្រកម្ពុជាសិន ។ នេះគឺជាភាពត្រឹមត្រូវតាមច្បាប់ និងដូចគ្នាទៅនឹងការងារមុនៗ ដែលអនុវត្តរវាងខ្ញុំ និងសហចៅក្រមស៊ើបអង្កេតអន្តរជាតិមុនៗ"*[3] ។ នៅក្នុងសេចក្តីប្រកាសព័ត៌មានតបរបស់ខ្លួនចុះថ្ងៃទី ០៦ ខែធ្នូ ឆ្នាំ ២០១១ និងសេចក្តីប្រកាសព័ត៌មានតបជាបន្តបន្ទាប់ សហចៅក្រមស៊ើបអង្កេតជាតិនៅតែរក្សានូវគោលជំហរនេះរហូត។

[3] អនុស្សរណៈផ្ទៃក្នុង របស់សហចៅក្រមស៊ើបអង្កេតជាតិ ចុះថ្ងៃទី០៥ ខែ ធ្នូ ឆ្នាំ ២០១១ ។

ការរក្សានូវគោលជំហរក្នុងការបកស្រាយវិធាន ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងកិច្ចព្រមព្រៀង គឺជាការបញ្ចេញនូវគោលជំហររបស់ចៅក្រមវិជ្ជាជីវៈម្នាក់តែប៉ុណ្ណោះ មិនមែនជាការប្រឆាំងទៅនឹងសហចៅក្រម Laurent Kasper Ansermet ទេ ជាក់ស្តែងនាពេលថ្មីនេះ សហចៅក្រមស៊ើបអង្កេតជាតិបានអញ្ជើញសហចៅក្រមស៊ើបអង្កេតបម្រុងទៅពិសារអាហារពេលល្ងាចនៅភោជនីយដ្ឋានមួយក្នុងទីក្រុងភ្នំពេញ ដែលអាហារល្ងាចនេះត្រូវបានលោកចៅក្រម Laurent Kasper Ansermet ចាត់ទុកថាជាការជួបប្រជុំក្រៅផ្លូវការនៅក្នុងសេចក្តីប្រកាសព័ត៌មានរបស់លោក។

**២. ការខ្វែងយោបល់គ្នាស្របតាមវិធាន ៧២**

បន្ទាប់ពីកិច្ចប្រជុំថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១១ លោកសហចៅក្រមស៊ើបអង្កេតបម្រុង Laurent Kasper Ansermet បានដាក់នូវការខ្វែងយោបល់គ្នាលើកិច្ចនីតិវិធីក្នុងសំណុំរឿង ០០៣ និង ០០៤ ជាបន្តបន្ទាប់មកសហចៅក្រមជាតិ ដោយមិនមានការពិគ្រោះយោបល់ ឬពិភាក្សាអ្វីឡើយ ដោយគ្រាន់តែសំអាងលើអនុស្សរណៈផ្ទៃក្នុង របស់សហចៅក្រមស៊ើបអង្កេតជាតិ ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១១ តែប៉ុណ្ណោះ។ មិនត្រឹមតែប៉ុណ្ណោះ លោកសហចៅក្រមស៊ើបអង្កេតបម្រុង បានធ្វើការប្រកាសព័ត៌មានជាសាធារណៈដោយរំលោភលើវិធាន ៥៦ម្តងហើយម្តងទៀត ដោយមិនមានការពិភាក្សាជាមួយសហចៅក្រមស៊ើបអង្កេតជាតិឡើយ។

ជាការឆ្លើយតប សហចៅក្រមស៊ើបអង្កេតជាតិបានធ្វើសេចក្តីប្រកាសព័ត៌មានបន្តបន្ទាប់ ដើម្បីជៀសវៀងការភ័ន្តច្រឡំនានាក្នុងមតិសាធារណៈ និងបានបញ្ជាក់ច្បាស់លាស់នូវគោលជំហររបស់ខ្លួន ក៏ដូចជារំលឹកដាស់តឿនលោកសហចៅក្រមបម្រុងអន្តរជាតិអំពីកំហុសឆ្គងរបស់គាត់។

ដោយនៅតែទទួលបានជាបន្តបន្ទាប់នូវកំណត់ហេតុខ្វែងយោបល់ពីសហចៅក្រមបម្រុងអន្តរជាតិ សហចៅក្រមស៊ើបអង្កេតជាតិបានបង្គាប់ទៅក្រឡាបញ្ជីជាតិ និងជំនួយការរដ្ឋបាលថា ឈប់ទទួលឯកសារពីសហចៅក្រមបម្រុងអន្តរជាតិ ដែលជាឯកសារខ្វែងយោបល់ ដោយហេតុថាសហចៅក្រមស៊ើបអង្កេតជាតិមិនដែលពិភាក្សាអំពីកិច្ចនីតិវិធីណាមួយជាមួយលោកសហចៅក្រមស៊ើបអង្កេតបម្រុងឡើយ ហើយក៏គ្មានការខ្វែងយោបល់គ្នាអំពីកិច្ចនីតិវិធីណាមួយដែរ។ លើសពីនេះ នាថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ ២០១២ សហចៅក្រមជាតិបានផ្ញើលិខិតមួយក្រោមទម្រង់ជាលិខិតសម្ងាត់ទៅសហចៅក្រមបម្រុងដើម្បីជាការដាស់តឿន ក៏ដូចជាបញ្ជាក់ជាថ្មីនូវគោលជំហររបស់សហចៅក្រមស៊ើបអង្កេតជាតិ ព្រមទាំងការទាមទារឲ្យបញ្ឈប់ការប្រើប្រាស់ឈ្មោះរបស់សហចៅក្រមជាតិទាក់ទិនទៅនឹងទង្វើ ឬកិច្ចនានាដែលធ្វើឡើងជាឯកតោភាគីរបស់សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ។

ចំពោះចំនុចនេះ សហចៅក្រមស៊ើបអង្កេតជាតិសូមគូសបញ្ជាក់ឲ្យសាធារណជនបានជ្រាបច្បាស់ថា ពាក្យខ្វែងយោបល់អំពីកិច្ចនីតិវិធី ដោយយោងតាមវិធាន ៧២ នៃវិធានផ្ទៃក្នុងគឺគ្មានទាល់តែសោះ ប៉ុន្តែការជំទាស់របស់សហចៅក្រមស៊ើបអង្កេតជាតិ នៅក្នុងករណីនេះ គឺ ដោយសារតែលោក Laurent Kasper Ansermet គ្មាននីតិសម្បទាតាមផ្លូវច្បាប់ ហើយវិធានផ្ទៃក្នុង និងច្បាប់ ក៏មិនបានបញ្ញត្តិបម្រុងទុកក្នុងករណីនេះដែរ ដូច្នេះត្រូវដោះស្រាយបញ្ហានេះជាមុនសិន។ សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិមិនគួរណាយក

មតិយោបល់របស់ចៅក្រមណាមួយ ដែលមិនមែនជាអង្គដោះស្រាយបញ្ហានេះ មកអះអាងដើម្បីធ្វើកិច្ចដោយមិនបានពិចារណា ដល់វិធានច្បាប់ និងការអនុវត្តកន្លងមកនោះឡើយ។

## ៣. ការបដិសេធមិនដាក់ឯកសាររបស់សហចៅក្រមស៊ើបអង្កេតបម្រុងចូលក្នុងសំណុំរឿង

ជាគោលការណ៍ សហចៅក្រមស៊ើបអង្កេតគឺជាម្ចាស់ និងជាអ្នកគ្រប់គ្រងសំណុំរឿងស៊ើបសួរ គ្មានឯកសារនៃសំណុំរឿងណាមួយអាចត្រូវបានដាក់ដោយគ្មានការឯកភាពពីសហចៅក្រមស៊ើបអង្កេតទាំងពីរឡើយ។ ដោយហេតុថា លោក Laurent Kasper Ansermet មិនមាននីតិសម្បទាក្នុងការសម្រេចអំពីការដាក់ឯកសារចូលក្នុងសំណុំរឿងនេះ សហចៅក្រមស៊ើបអង្កេតជាតិ មិនបានសម្រេចឲ្យដាក់ឯកសារណាមួយចូលក្នុងសំណុំរឿងឡើយចាប់តាំងពីពេលដែលចៅក្រម Siegfried Blunk ចាកចេញទៅ លើកលែងតែពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលបានទទួលក្នុងរយៈពេលចៅក្រម Blunk កាន់តំណែង ដោយហេតុថា មានការឯកភាពរវាងសហចៅក្រមជាតិ និង លោកចៅក្រម Blunk ឲ្យដាក់ពាក្យសុំទាំងនេះចូលក្នុងសំណុំរឿង។ ហេតុដូចនេះ ក្នុងនាមជាចៅក្រមពេញសិទ្ធិ និងជាអ្នកគ្រប់គ្រងសំណុំរឿងស៊ើបសួរមួយរូប សហចៅក្រមស៊ើបអង្កេតជាតិ មិនអនុញ្ញាតឲ្យមានការកែប្រែនូវស្ថានភាពណាមួយនៃសំណុំរឿង ដែលធ្វើឡើងដោយសហចៅក្រមបម្រុងដែលមិនមានសិទ្ធិនោះទេ។ នៅក្នុងបរិបទនេះហើយ ដែលលោកសហចៅក្រមបម្រុង Laurent Kasper Ansermet បានបើកការស៊ើបសួរអំពីការជ្រៀតជ្រែកក្នុងកិច្ចការតុលាការនៃវិធាន ៣៥ ប្រឆាំងទៅនឹងមន្ត្រីគ្រប់គ្រងសំណុំរឿង និង ប្រធានផ្នែកគ្រប់គ្រងតុលាការ ដោយហេតុថា ពួកគេអនុវត្តតាមបញ្ជារបស់សហចៅក្រមស៊ើបអង្កេតជាតិ ដែលតម្រូវមិនឲ្យមានការកែប្រែស្ថានការសំណុំរឿង ដរាបណាមានសេចក្តីសម្រេចតុលាការដែលធ្វើឡើងស្របតាមបទប្បញ្ញត្តិនៃវិធានផ្ទៃក្នុង ច្បាប់ស្តីពីការបង្កើតអ.វ.ត.ក និងកិច្ចព្រមព្រៀង ។ ការបើកការស៊ើបសួរក្រោមវិធាន ៣៥ នេះត្រូវបានធ្វើឡើងផងដែរប្រឆាំងនឹងប្រធានក្រុមអ្នកច្បាប់ជាតិ នៃការិយាល័យសហចៅក្រមស៊ើបអង្កេត ដោយគ្រាន់តែគាត់ពាំនាំនូវបញ្ជារបស់សហចៅក្រមជាតិទៅកាន់ផ្នែកគ្រប់គ្រងតុលាការតែប៉ុណ្ណោះ។ ការប្តឹងនេះមិនចំណេញអ្វីដល់សំណុំរឿងឡើយ ប៉ុន្តែវាជាការគម្រាមកំហែងយ៉ាងច្បាស់លាស់ទៅនឹងមន្ត្រីណាដែលជំទាស់នឹងបញ្ជារបស់សហចៅក្រមស៊ើបអង្កេតបម្រុង បើទោះបីជាបញ្ជាទាំងនោះត្រូវបានអនុវត្តរួចរាល់ហើយដោយបុគ្គលិកនៅក្នុងការិយាល័យរដ្ឋបាលក៏ដោយ។

## ៤. ការបដិសេធមិនឲ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណីចូលមើលសំណុំរឿងបន្ទាប់ពីមានដីកាទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណី

ដោយហេតុថា សហចៅក្រមស៊ើបអង្កេតបម្រុងមិនមាននីតិសម្បទានៅក្នុងបំពេញកិច្ចនីតិវិធី ដូចនេះ អ្វីដែលសហចៅក្រមបម្រុងនេះសម្រេចក៏គ្មានសុពលភាពដែរ។ ហេតុដូចនេះ ការបដិសេធរបស់មន្ត្រីគ្រប់គ្រងតុលាការគឺជាការត្រឹមត្រូវ ដោយហេតុថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក Rob Hamill ត្រូវបានបដិសេធដោយសហចៅក្រមស៊ើបអង្កេតជាតិ និងសហចៅក្រម Siegfried Blunk រួចហើយ ហើយអង្គបុរេជំនុំជម្រះក៏បានសម្រេចលើបណ្តឹងឧទ្ធរណ៍នេះផងដែរ។

ចំណែកឯការភ្ជាប់បញ្ហានេះទៅនឹងការហាមឃាត់មិនឲ្យប្រធានក្រុមអ្នកច្បាប់អន្តរជាតិចូលក្នុងការិយាល័យនៃផ្នែកគ្រប់គ្រងតុលាការគឺជាការបំផ្លើសទាំងស្រុង ដោយហេតុថា នៅក្នុងសារអេឡិកត្រូនិកចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១២ ដែលផ្ញើទៅប្រធានក្រុមអ្នកច្បាប់អន្តរជាតិ និងចម្លងជូនសហចៅក្រមស៊ើបអង្កេតជាតិ សហចៅក្រមបម្រុង និងប្រធានស្តីទី និងអនុប្រធានការិយាល័យរដ្ឋបាល ប្រធានផ្នែកគ្រប់គ្រងតុលាការបានបញ្ជាក់ច្បាស់អំពីទង្វើអសីលធម៌ និងគ្មានវិជ្ជាជីវៈរបស់ប្រធានក្រុមអ្នកច្បាប់អន្តរជាតិ។ ទង្វើអសីលធម៌និងភាពគ្មានវិជ្ជាជីវៈនេះមិនមានអ្វីចម្លែកទេចំពោះសហចៅក្រមស៊ើបអង្កេតជាតិ ដោយហេតុថា សហចៅក្រមស៊ើបអង្កេតជាតិ និងសហចៅក្រម Siegfried Blunk បានប្តឹងទៅមន្ត្រីរបស់អង្គការសហប្រជាជាតិចំនួនពីរដងហើយចំពោះទង្វើអសីលធម៌របស់ប្រធានក្រុមអ្នកច្បាប់អន្តរជាតិនេះ ដោយសារគាត់បានហៅចៅក្រម Siegfried Blunk ពី ក្រោយខ្នងថា "Connard= Damn Fool or Jackass" ។

នៅក្នុងករណីនេះ សហចៅក្រមស៊ើបអង្កេតជាតិ បានវាយតម្លៃខ្ពស់ចំពោះគោលជំហររបស់លោកចៅក្រម Siegfried Blunk ដែលបានលើកឡើងថា "*ក្នុងនាមជាចៅក្រម គឺត្រូវធ្វើការសម្រេចសេចក្តីដោយខ្លួនឯង មិនមែនធ្វើតាមអ្វីដែលមន្ត្រីច្បាប់ និងមជ្ឈដ្ឋានខាងក្រៅរបស់ខ្លួនដាក់សម្ពាធមកលើខ្លួននោះឡើយ*"។

**៥. ការដកហូតត្រាផ្លូវការរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត**

សហចៅក្រមស៊ើបអង្កេតជាតិសូមគូសបញ្ជាក់ថា នៅពេលដែលចៅក្រម Marcel Lemonde និងចៅក្រម Siegfried Blunk ជាសហចៅក្រមស៊ើបអង្កេត ការិយាល័យក្រឡាបញ្ជីមានតែមួយដែលក្នុងនោះមានក្រឡាបញ្ជីជាតិ និងអន្តរជាតិអង្គុយរួមគ្នា ដែលត្រាត្រូវបានរក្សាទុកដោយក្រឡាបញ្ជីជាតិ និងធ្វើការជាអង្គភាពតែមួយ។ នៅថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ ២០១២ លោកសហចៅក្រមបម្រុង Laurent Kasper Ansermet បានបំបែកក្រឡាបញ្ជីអន្តរជាតិចេញពីបន្ទប់ក្រឡាបញ្ជី ដោយមិនមានការជូនដំណឹងណាមួយ ឬការពន្យល់ហេតុផលណាមួយដល់សហចៅក្រមជាតិឡើយ។

នាថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១២ ក្រឡាបញ្ជីជាតិបានសុំការអនុញ្ញាតពីសហចៅក្រមជាតិដើម្បីយកត្រាផ្លូវការរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតទុកក្នុងបន្ទប់របស់ហចៅក្រមជាតិ ដោយហេតុថាខ្លួនទទួលបាននូវការគម្រាមកំហែងពីសំណាក់សហចៅក្រមបម្រុងអន្តរជាតិតាមរយៈក្រឡាបញ្ជីអន្តរជាតិ ថាខ្លួននឹងត្រូវបានប្តឹងពីការជ្រៀតជ្រែកចូលកិច្ចការតុលាការក្រោមវិធាន ៣៥ ដូចមន្ត្រីគ្រប់គ្រងតុលាការដែរប្រសិនបើខ្លួនមិនព្រមវាយត្រាលើរាល់ឯកសាររបស់លោក Laurent Kasper Ansermet នោះទេ។ ការសម្រេចនេះ ត្រូវបានធ្វើឡើងបន្ទាប់ពីខ្លួនបានឃើញវត្តមានរបស់លោក Laurent Kasper Ansermet និងក្រឡាបញ្ជីអន្តរជាតិរបស់លោកនៅក្នុងបន្ទប់ក្រឡាបញ្ជីជាតិដោយគ្មានការអនុញ្ញាត នៅពេលដែលក្រឡាបញ្ជីជាតិមិនមានវត្តមាននៅក្នុងបន្ទប់[4]។ នាថ្ងៃទី ២០ ខែកុម្ភះ ឆ្នាំ ២០១២ លោកសហចៅក្រមបម្រុង បានធ្វើលិខិតមួយបញ្ជាសហចៅក្រមជាតិ ឲ្យធ្វើនិយ័តកម្មចំពោះស្ថានភាពដែលបានលើកឡើងនេះ ក្នុងអំឡុង

---

[4] កំណត់ហេតុដែលធ្វើឡើងដោយក្រឡាបញ្ជីជាតិ ចុះថ្ងៃទី ១៣ ខែ កុម្ភះ ឆ្នាំ ២០១២ ។

ពេល ២៤ ម៉ោង គឺរហូតដល់១ថ្ងៃបន្ទាប់ នាម៉ោង ៤ រសៀល ប្រសិនបើមិនដូចនេះទេ គាត់គម្រាមថាគាត់នឹងចាត់វិធានការតាមច្បាប់ចាំបាច់[5] ។ សហចៅក្រមស៊ើបអង្កេតជាតិ មិនឆ្លើយតបទៅនឹងការគម្រាមកំហែងនេះទេ។

## ៦. ការរាំងស្ទះដល់ការស៊ើបអង្កេតផ្ទៃក្នុង

ដូចបានគូសបញ្ជាក់ខាងលើ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង បានយកវិធានការក្នុងវិធាន ៣៥ ជាអាវុធក្នុងការគម្រាមកំហែងមន្ត្រីនានានៅក្នុងអ.វ.ត.ក ដោយរួមមានទាំងបុគ្គលិកជាតិ និងបុគ្គលិកអន្តរជាតិ។

នាថ្ងៃទី ២០ ខែមករា ឆ្នាំ ២០១២ ពាក់ព័ន្ធនឹងការបើកការស៊ើបអង្កេតលើការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលក្រោមវិធាន ៣៥ លោកសហចៅក្រមស៊ើបអង្កេតបម្រុងបានចេញនូវដីកាចាត់ឲ្យស៊ើបសួរជំនួសមួយ ដោយបង្គាប់ឲ្យមានការស្តាប់ចម្លើយលោក Christopher Ankersen ប្រធានផ្នែកសន្តិសុខ និងសុវត្ថិភាព និងលោក Soe U Myint ប្រធានផ្នែកបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យា ទាក់ទងទៅនឹងការមិនអនុវត្តតាមសំណើរបស់ អ្នកស៊ើបអង្កេត Paolo PASTORE STOCCHI ដែលបានផ្ញើទៅពួកគេនាថ្ងៃទី ២៨ ខែកញ្ញា ឆ្នាំ ២០១១។ ការចេញនូវដីកាចាត់ឲ្យស៊ើបសួរជំនួសនេះគឺផ្អែកតែទៅលើរបាយការណ៍ផ្ទាល់របស់ លោក Paolo PASTORE STOCCHI ដែលជារបាយការណ៍ធ្វើឡើងដើម្បីបិទបាំងកំហុសវិជ្ជាជីវៈរបស់ខ្លួនប៉ុណ្ណោះ ដោយហេតុថា ទាក់ទិនទៅនឹងការស៊ើបសួរក្រោមវិធាន ៣៥ ដែលបើកដោយសហចៅក្រមស៊ើបអង្កេតជាតិ និងសហចៅក្រម Siegfried Blunk លោក Paolo PASTORE STOCCHI បានប្រព្រឹត្តនូវកំហុសវិជ្ជាជីវៈធ្ងន់ធ្ងរដោយរំលោភលើដីកាចាត់ឲ្យស៊ើបសួរជំនួសរបស់សហចៅក្រមស៊ើបអង្កេតចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១១ ហើយកំហុសវិជ្ជាជីវៈនេះក៏ត្រូវបានប្ដឹងទៅលោកស្រី Patricia O′ Brien ប្រធានកិច្ចការច្បាប់របស់អង្គការសហប្រជាជាតិ ក្នុងលិខិតចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១១ រួចហើយផងដែរ។ ម្យ៉ាងវិញទៀត ការចេញនូវដីកាចាត់ឲ្យស៊ើបសួរជំនួសរបស់លោក Laurent Kasper Ansermet គឺធ្វើឡើងទាំងទទឹងទិស ទោះបីជាមានការពន្យល់យ៉ាងត្រឹមត្រូវ និងការផ្ញើជូននូវឯកសារសម្អាង អំពីការពិតដោយលោក Knut Rosandhaug ទៅកាន់ខ្លួនតាមរយៈសារអេឡិកត្រូនិកចុះថ្ងៃទី ១៧ ខែមករា ឆ្នាំ២០១២ ក៏ដោយ។

សហចៅក្រមស៊ើបអង្កេតជាតិមិនដែលចេញបញ្ជាណាមួយដល់ប្រធានក្រុមអ្នកច្បាប់ជាតិ និងមន្ត្រីផ្សេងទៀតរបស់អ.វ.ត.ក ក្នុងការឆ្លើយតបទៅនឹងការកោះហៅដែលធ្វើឡើងដោយអ្នកស៊ើបអង្កេតអន្តរជាតិឡើយ ប៉ុន្តែសហចៅក្រមស៊ើបអង្កេតជាតិយល់ឃើញថា ការឆ្លើយតបរបស់ប្រធានក្រុមអ្នកច្បាប់ជាតិ និងការមិនឆ្លើយតបរបស់បុគ្គលិកជាតិ និងបុគ្គលិកអន្តរជាតិ ដែលមានចំណេះដឹងគ្រប់គ្រាន់អំពីគោលការណ៍ច្បាប់ដែលអនុវត្តនៅអ.វ.ត.ក គឺជាប្រតិកម្មយ៉ាងសមស្របបំផុតទៅនឹងការគម្រាមកំហែងរបស់លោកសហចៅក្រម

---

[5] លិខិតរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១២ ។

បម្រុង Laurent Kasper Ansermet ដែលជាសហចៅក្រមគ្មានសិទ្ធិ។ ការចោទប្រកាន់ថា មានការរាំងស្ទះដល់ការស៊ើបសួរផ្ទៃក្នុងដែលលើកឡើងដោយលោក Laurent Kasper Ansermet ដោយទម្លាក់កំហុសមកលើបុគ្គលិកជាតិ និងសហចៅក្រមស៊ើបអង្កេតគឺជាការបំផ្លើសពីការពិតទាំងស្រុង។

ចំពោះការសន្និដ្ឋានអំពីអនីយ័តភាព ការមិនដំណើរការ និងការរំលោភលើគោលការណ៍នីតិវិធីរបស់លោក Laurent Kasper Ansermet សហចៅក្រមស៊ើបអង្កេតជាតិយល់ឃើញថា៖

១. ចំណាត់ការនៃសំណុំរឿង ០០៣ និង ០០៤ ត្រូវបានធ្វើឡើងចាប់តាំងពីរយៈពេលនៃចៅក្រម Marcel Lemonde និង Siegfried Blunk ដោយមិនមានបញ្ហាណាមួយឡើយ ទោះបីជាចំណាត់ការទាំងនោះមានការឯកភាពគ្នាខ្លះ មិនឯកភាពគ្នាខ្លះរវាងសហចៅក្រមស៊ើបអង្កេតទាំងពីរក៏ដោយ។

២. សំណុំរឿង ០០៣ និង ០០៤ ត្រូវបានបង្អង់ចាប់តាំងពីការចាកចេញរបស់លោកចៅក្រម Siegfried Blunk ដោយហេតុថា មិនមានការតែងតាំងចៅក្រមណាមួយជាផ្លូវការមកជំនួសចៅក្រមនេះ ដើម្បីបន្តកិច្ចនីតិវិធីដែលបាន និងកំពុងធ្វើ បើទោះបីជាដំណោះស្រាយតាមផ្លូវតុលាការចំពោះសំណុំរឿងទាំងនេះត្រូវបានឯកភាពគ្នាស្ទើរតែ ១០០ ភាគរយរវាងសហចៅក្រមស៊ើបអង្កេតជាតិ និងសហចៅក្រម Blunk ក៏ដោយ។

៣. សហចៅក្រមស៊ើបអង្កេតជាតិនៅតែអះអាងថា ខ្លួនមិនដែលជំទាស់ទៅនឹងកិច្ចនីតិវិធីណាមួយជាមួយនឹងលោក Laurent Kasper Ansermet នោះឡើយ គ្រាន់តែសហចៅក្រមស៊ើបអង្កេតជាតិមិនទទួលស្គាល់អំពីសុពលភាពគតិយុត្តិរបស់កិច្ចការនីតិវិធីទាំងឡាយណាដែលធ្វើដោយសហចៅក្រមបម្រុងរូបនេះប៉ុណ្ណោះ។

៤. សហចៅក្រមស៊ើបអង្កេតជាតិសូមគូសបញ្ជាក់បន្ថែមថា សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិចោទថា មានការរាំងស្ទះ ឬជ្រៀតជ្រែកដល់ការងាររបស់ខ្លួន ប៉ុន្តែជាក់ស្តែង តាមការប្រកាសព័ត៌មានរបស់ខ្លួនបានបញ្ជាក់ថា សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិបានចុះទៅបំពេញការងារនៅតាមបណ្តាខេត្តជាច្រើន និងជាពិសេសនាពេលនេះ បន្ទាប់ពីការប្រកាសព័ត៌មានរបស់ខ្លួន សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងកំពុងតែធ្វើការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងបន្ទប់សវនាការតូចរបស់អ.វ.ត.ក ទៀតផង។

៥. ទោះបីជាយ៉ាងណាក៏ដោយ សហចៅក្រមជាតិសូមស្វាគមន៍ចំពោះការលាលែងរបស់សហចៅក្រមបម្រុង Laurent Kasper-Ansermet ដោយសហចៅក្រមស៊ើបអង្កេតជាតិចាត់ទុកថា ការលាលែងនេះគឺជាការទទួលខុសត្រូវចំពោះកំហុសឆ្គងវិជ្ជាជីវៈ ក៏ដូចជាកំហុសឆ្គងនីតិវិធី ដែលបានធ្វើនាពេលកន្លងមក ទោះបីជាមានការដាស់តឿនម្តង ហើយម្តងទៀតពីសំណាក់សហចៅក្រមស៊ើបអង្កេតជាតិក៏ដោយ។

៦. សហចៅក្រមស៊ើបអង្កេតជាតិបានប្រកាន់ជំហរទទួលខុសត្រូវខ្ពស់ និងតែងតែទទួលស្គាល់ និងរៀនសូត្របទពិសោធន៍ល្អៗប្រកបដោយវិជ្ជាជីវៈ សម្រាប់ជាកេរដំណែលដល់តុលាការជាតិជានិច្ច។